# ព្រះរាជក្រម

នស/រកម/០៦១០/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិ-បត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុល រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពពស.១០០៦.៥៤៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ហត្ថលេខា

ហោ ណាំហុង

លេខ: ៥៨៦ ទ.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន មិនកេន

# អនុសញ្ញាកុងស៊ុល

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# សាធារណរដ្ឋប្រជាមានិតចិន

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលអំណើះតទៅហៅថា "ភាគីចុះកិច្ចសន្យា"

ដោយមានបំណងពង្រីកទំនាក់ទំនងកុងស៊ុល ដើម្បីសម្រួលដល់កិច្ចការពារសិទ្ធិ និងផលប្រយោជន៍របស់ជាតិ និងពលរដ្ឋ និងដើម្បីជំរុញនូវទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ

បានសម្រេចធ្វើអនុសញ្ញាកុងស៊ុលនេះ ដោយព្រមព្រៀងគ្នា ដូចតទៅ ៖

## ជំពូកទី១
## និយមន័យ

### មាត្រា១
### និយមន័យ

ក្នុងក្របខណ្ឌអនុសញ្ញានេះ ពាក្យពេចន៍ដែលមានខាងក្រោម មានន័យដូចតទៅ ៖

ក- "ប៉ុស្តិ៍កុងស៊ុល" មានន័យថា ស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុល ស្ថានអនុកុងស៊ុល ឬទីភ្នាក់ងារកុងស៊ុល

ខ- "មណ្ឌលកុងស៊ុល" មានន័យថា តំបន់ដែលបានកំណត់ប៉ុស្តិ៍កុងស៊ុលណាមួយ ដើម្បីបំពេញមុខងារកុងស៊ុល

គ- "ប្រធានប៉ុស្តិ៍កុងស៊ុល" មានន័យថា អគ្គកុងស៊ុល កុងស៊ុល អនុកុងស៊ុល ឬ ភ្នាក់ងារកុងស៊ុល ដែលត្រូវបានចាត់តាំងដោយរដ្ឋដាក់កុងស៊ុល ឱ្យដឹកនាំប៉ុស្តិ៍កុងស៊ុលមួយ

ឃ- "មន្ត្រីកុងស៊ុល" មានន័យថា អគ្គកុងស៊ុល អគ្គកុងស៊ុលរង កុងស៊ុល អនុកុងស៊ុល អនុព័ន្ធកុងស៊ុល ឬ ភ្នាក់ងារកុងស៊ុល

ង- "សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃប៉ុស្តិ៍កុងស៊ុល" មានន័យថា ជនទាំងឡាយណាបំពេញការងារសេវារដ្ឋបាល ឬបច្ចេកទេស នៅក្នុងប៉ុស្តិ៍កុងស៊ុល

ច- "សមាជិកនៃបុគ្គលិកបម្រើការងារ" មានន័យថា ជនទាំងឡាយណា ដែលចាត់ឱ្យទៅបម្រើការងារផ្ទះ នៅក្នុងប៉ុស្តិ៍កុងស៊ុល

ឆ- "សមាជិកនៃប៉ុស្តិ៍កុងស៊ុល" មានន័យថា មន្ត្រីកុងស៊ុល សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស និងសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល

ជ- "សមាជិកគ្រួសារ" មានន័យថា ភរិយា/ស្វាមី របស់សមាជិកនៃប៉ុស្តិ៍កុងស៊ុល និងកូនជាអនីតិជនដែលរស់នៅជាមួយគ្នា

ឈ- "សមាជិកនៃបុគ្គលិកឯកជន" មានន័យថា រាល់ជន ដែលចាត់ឱ្យបម្រើការងារឯកជនរបស់សមាជិកនៃប៉ុស្តិ៍កុងស៊ុល

ញ- "ទីស្ថានកុងស៊ុល" មានន័យថា អគារ ឬផ្នែកនានានៃអគារ និងផ្ទៃដីជាប់នឹងអគារនោះ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ឱ្យតែប្រើប្រាស់ផ្តាច់មុខ សម្រាប់ផលប្រយោជន៍របស់ប៉ុស្តិ៍កុងស៊ុល

ដ- "បណ្ណសារកុងស៊ុល" មានន័យថា រាល់ក្រដាសស្នាម ឯកសារ លិខិតឆ្លើយឆ្លង សៀវភៅមើល ខ្សែភាពយន្ត ខ្សែអាត់សំឡេង សៀវភៅចុះបញ្ជីរបស់ប៉ុស្តិ៍កុងស៊ុល ព្រមទាំងលេខ និងអក្សរសម្ងាត់ បញ្ជីឯកសារ ទិន្នន័យរក្សាទុកក្នុងឧបករណ៍ចងចាំ និងរាល់គ្រឿងសង្ហារិម ប្រើប្រាស់សម្រាប់តម្កល់ទុក ឬការពារសុវត្ថិភាពឯកសារទាំងនោះ

ឋ- "ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល" មានន័យថា រាល់រូបវន្តបុគ្គលដែលមានសញ្ជាតិនៃរដ្ឋដាក់កុងស៊ុល ព្រមទាំងនីតិបុគ្គលនៃរដ្ឋដាក់កុងស៊ុល

ឌ- "នាវនៃរដ្ឋដាក់កុងស៊ុល" មានន័យថា រាល់នាវាស្របច្បាប់ ដែលមានដោតទង់ជាតិរដ្ឋដាក់កុងស៊ុល ដោយមិនរាប់បញ្ចូលនាវាយោធាទេ

ឍ- "យន្តហោះនៃរដ្ឋដាក់កុងស៊ុល" មានន័យថា យន្តហោះដែលបានចុះបញ្ជីត្រឹមត្រូវ ក្នុងរដ្ឋដាក់កុងស៊ុល និងមានសញ្ញាសម្គាល់របស់រដ្ឋនោះ ដោយមិនរាប់បញ្ចូលយន្តហោះយោធាទេ។

## ជំពូកទី២
## ការបង្កើតប៉ុស្តិ៍កុងស៊ុល និងការតែងតាំងសមាជិក

### មាត្រា២
### ការបង្កើតប៉ុស្តិ៍កុងស៊ុល

១-ប៉ុស្តិ៍កុងស៊ុលអាចបង្កើតនៅក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះបាន លុះត្រាតែមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ។

២-អាសនៈប៉ុស្តិ៍កុងស៊ុល លំដាប់ថ្នាក់ និងមណ្ឌលកុងស៊ុល ព្រមទាំងការផ្លាស់ប្តូរណាមួយ ត្រូវបានកំណត់ដោយរដ្ឋដាក់កុងស៊ុល និងត្រូវបានយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ។

### មាត្រា៣
### ការតែងតាំង និងការទទួលស្គាល់ជាប្រធានប៉ុស្តិ៍កុងស៊ុល

១-រដ្ឋដាក់កុងស៊ុលត្រូវបញ្ជូនទៅរដ្ឋម្ចាស់ផ្ទះ តាមរយៈផ្លូវទូត នូវលិខិតតែងតាំងប្រធានប៉ុស្តិ៍កុងស៊ុល។ លិខិតនេះត្រូវបញ្ជាក់នាមត្រកូល និងនាមខ្លួន ឋានៈរបស់ប្រធានប៉ុស្តិ៍កុងស៊ុល អាសនៈ និងលំដាប់ថ្នាក់ ព្រមទាំងមណ្ឌលកុងស៊ុល។

២-ក្រោយពីទទួលបានលិខិតតែងតាំងប្រធានប៉ុស្តិ៍កុងស៊ុល រដ្ឋម្ចាស់ផ្ទះត្រូវឆ្លើយតបលើការតែងតាំងឱ្យបានឆាប់បំផុត ដែលអាចធ្វើទៅបាន។ ប្រសិនបើ រដ្ឋម្ចាស់ផ្ទះបដិសេធការឆ្លើយតប រដ្ឋម្ចាស់ផ្ទះមិនចាំបាច់បញ្ជាក់ពីមូលហេតុនៃការបដិសេធនេះទេ។

៣-ប្រធានប៉ុស្តិ៍កុងស៊ុលអាចចូលបំពេញមុខងាររបស់ខ្លួន ក្រោយពីរដ្ឋម្ចាស់ផ្ទះចេញលិខិតយល់ព្រមលើការតែងតាំង។ ក្នុងពេលរង់ចាំលិខិតយល់ព្រម ប្រធានប៉ុស្តិ៍កុងស៊ុលអាចបំពេញមុខងាររបស់ខ្លួនជាបណ្តោះអាសន្នបាន ដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ។

៤-នៅពេលប្រធានប៉ុស្តិ៍កុងស៊ុលទទួលការអនុញ្ញាតឱ្យបំពេញមុខងាររបស់ខ្លួនទោះក្នុងលក្ខណៈបណ្តោះអាសន្នក្តី រដ្ឋម្ចាស់ផ្ទះត្រូវជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ច នៅក្នុងមណ្ឌលកុងស៊ុល និងចាត់វិធានការចាំបាច់នានា ដើម្បីឱ្យប្រធានប៉ុស្តិ៍កុងស៊ុលបំពេញមុខងាររបស់ខ្លួន ព្រមទាំងទទួលបានសិទ្ធិ ការសម្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ។

## មាត្រា៤
## ការអនុវត្តមុខងារជាបណ្តោះអាសន្នរបស់ប្រធានប៉ុស្តិ៍កុងស៊ុល

១-ប្រសិនបើ ប្រធានប៉ុស្តិ៍កុងស៊ុលមិនអាចបំពេញមុខងាររបស់ខ្លួន ដោយសារហេតុផលណាមួយ ឬប្រសិនបើ តំណែងប្រធានប៉ុស្តិ៍កុងស៊ុលនៅទំនេរជាបណ្តោះអាសន្ន រដ្ឋដាក់កុងស៊ុលអាចចាត់តាំងមន្ត្រីកុងស៊ុលនៃប៉ុស្តិ៍កុងស៊ុល ឬប៉ុស្តិ៍កុងស៊ុលផ្សេងទៀតក្នុងរដ្ឋម្ចាស់ផ្ទះ ឬមន្ត្រីការទូតនៃស្ថានទូតខ្លួនក្នុងរដ្ឋម្ចាស់ផ្ទះ ជាប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី។ រដ្ឋដាក់កុងស៊ុលត្រូវជូនដំណឹងទៅរដ្ឋម្ចាស់ផ្ទះជាមុន អំពីនាមត្រកូល និងនាមខ្លួន និងឋានៈរបស់ប្រធានប៉ុស្តិ៍កុងស៊ុលស្តីទីនេះ។

២-ប្រធានប៉ុស្តិ៍កុងស៊ុលស្តីទីត្រូវទទួលបានសិទ្ធិ ភាពងាយស្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចប្រធានប៉ុស្តិ៍កុងស៊ុលមុន ស្របតាមអនុសញ្ញានេះ។

៣-មន្ត្រីការទូត ដែលចាត់តាំងឱ្យធ្វើជាប្រធានប៉ុស្តិ៍កុងស៊ុលស្តីទី ត្រូវបន្តទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូត។

## មាត្រា៥
## ការជូនដំណឹងអំពីការមកដល់ និងការចាកចេញ

រដ្ឋដាក់កុងស៊ុលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋម្ចាស់ផ្ទះ នៅពេលវេលាណាមួយសមស្រប ដូចខាងក្រោម ៖

ក-នាមត្រកូល និងនាមខ្លួន និងឋានៈសមាជិកនៃប៉ុស្តិ៍កុងស៊ុល កាលបរិច្ឆេទនៃការមកដល់ និងការចាកចេញជាស្ថាពរ ឬការបញ្ចប់មុខងារ ព្រមទាំងការផ្លាស់ប្តូរផ្សេងទៀតក្នុងពេលបំពេញមុខងាររបស់ខ្លួន។

ខ-នាមត្រកូល និងនាមខ្លួន សញ្ជាតិ និងកាលបរិច្ឆេទនៃការមកដល់ និងការចាកចេញជាស្ថាពរនៃសមាជិកគ្រួសារ របស់សមាជិកប៉ុស្តិ៍កុងស៊ុល និងមូលហេតុដែលនាំឱ្យបុគ្គលណាម្នាក់ក្លាយជា ឬលែងជាសមាជិកនៃគ្រួសារនេះ។

គ-នាមត្រកូល និងនាមខ្លួន សញ្ជាតិ មុខងារ និងកាលបរិច្ឆេទនៃការមកដល់ និងការចាកចេញជាស្ថាពររបស់សមាជិកនៃបុគ្គលិកឯកជន។

## មាត្រា៦
## បណ្ណសម្គាល់

អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋម្ចាស់ផ្ទះ ស្របតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ខ្លួន ត្រូវចេញបណ្ណសម្គាល់ឱ្យសមាជិកនៃប៉ុស្តិ៍កុងស៊ុល ព្រមទាំងសមាជិកគ្រួសារ លើកលែងតែអ្នកទាំងនោះជាពលរដ្ឋរបស់រដ្ឋម្ចាស់ផ្ទះ ឬជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងរដ្ឋនោះ។

## មាត្រា៧
## សញ្ជាតិសមាជិកនៃប៉ុស្តិ៍កុងស៊ុល និងសមាជិកនៃបុគ្គលិកឯកជន

១-មន្ត្រីកុងស៊ុលត្រូវជាពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ហើយជាជនដែលគ្មានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍ នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

២-សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស និងសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល និងសមាជិកនៃបុគ្គលិកឯកជន ត្រូវជាពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ឬពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ។

## មាត្រា៨
## បុគ្គលមិនគួរឱ្យស្វាគមន៍

១-រដ្ឋម្ចាស់ផ្ទះអាចជូនដំណឹងទៅរដ្ឋដាក់កុងស៊ុល នៅពេលណាមួយ តាមរយៈផ្លូវទូតថា សមាជិកនៃប៉ុស្តិ៍កុងស៊ុលជាបុគ្គលមិនគួរទទួលស្វាគមន៍ ឬមិនអាចទទួលយកបាន ហើយរដ្ឋម្ចាស់ផ្ទះមិនចាំបាច់ផ្តល់ហេតុផលចំពោះការសម្រេចចិត្តនោះទេ។

២-ក្នុងករណីដូចបានរៀបរាប់ក្នុងកថាខណ្ឌ ១ នៃមាត្រានេះ រដ្ឋដាក់កុងស៊ុលអាចកោះហៅបុគ្គលនោះ ឱ្យត្រឡប់មកវិញ ឬបញ្ចប់មុខងាររបស់បុគ្គលនោះ។ ប្រសិនបើ រដ្ឋដាក់កុងស៊ុលខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងកាលវេលាមួយសមស្រប រដ្ឋម្ចាស់ផ្ទះអាចដកការយល់ព្រមពីបុគ្គលពាក់ព័ន្ធនោះ ឬឈប់ចាត់ទុកបុគ្គលនោះជាសមាជិកនៃប៉ុស្តិ៍កុងស៊ុល។

## ជំពូកទី៣
## មុខងារកុងស៊ុល

### មាត្រា៩
### មុខងារកុងស៊ុលទូទៅ

មន្ត្រីកុងស៊ុលត្រូវបានផ្តល់សិទ្ធិ ដើម្បីបំពេញមុខងារកុងស៊ុលដូចតទៅ ៖

ក-ការពារសិទ្ធិ និងផលប្រយោជន៍របស់រដ្ឋដាក់កុងស៊ុល និងរបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល។

ខ-ជំរុញការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ ទេសចរណ៍ និងអប់រំ រវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ ព្រមទាំងពង្រឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋទាំងពីរ។

គ-ស្វែងយល់បន្ថែមទៀត តាមមធ្យោបាយស្របច្បាប់ ពីស្ថានភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ ទេសចរណ៍ អប់រំ និងវិស័យដទៃទៀត នៅក្នុងរដ្ឋម្ចាស់ផ្ទះ ហើយធ្វើរបាយការណ៍ជូនរដ្ឋាភិបាលរបស់ខ្លួន។

ឃ-បំពេញមុខងារផ្សេងទៀតដែលរដ្ឋដាក់កុងស៊ុលប្រគល់ជូន ដែលច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ មិនហាមឃាត់ ឬមិនជំទាស់។

### មាត្រា១០
### ការស្នើសុំពាក់ព័ន្ធនឹងសញ្ជាតិ និងចុះបញ្ជីអត្រានុកូលដ្ឋាន

១-មន្ត្រីកុងស៊ុលត្រូវបានផ្តល់សិទ្ធិដើម្បី ៖

ក-ទទួលពាក្យស្នើសុំពាក់ព័ន្ធនឹងសញ្ជាតិ។

ខ-ចុះបញ្ជីពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល។

គ-ចុះបញ្ជីកំណើត និងមរណភាពរបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល។

ឃ-ផ្តល់បែបបទសុំរៀបអាពាហ៍ពិពាហ៍ ឱ្យពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល និងចេញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ឱ្យពលរដ្ឋទាំងនោះ។

២-បទប្បញ្ញត្តិក្នុងកថាខណ្ឌ ១ នៃមាត្រានេះមិនត្រូវឱ្យបុគ្គលពាក់ព័ន្ធ រួចផុតពីកាតព្វកិច្ចគោរពច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះឡើយ។

## មាត្រា១១
## ការផ្តល់លិខិតឆ្លងដែន និងទិដ្ឋាការ

មន្ត្រីកុងស៊ុលត្រូវបានផ្តល់សិទ្ធិដើម្បី ៖

ក-ទទួលពាក្យស្នើសុំ និងចេញលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងទៀតឱ្យពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល និងអាចយល់ព្រម ឬពន្យារសុពលភាព ឬធ្វើអសុពលកម្មលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរទាំងនោះ។

ខ-ទទួលពាក្យស្នើសុំ និងចេញទិដ្ឋាការឱ្យបុគ្គលទាំងឡាយណា ដែលនឹងធ្វើដំណើរទៅ ឬឆ្លងកាត់រដ្ឋដាក់កុងស៊ុល និងអាចយល់ព្រម ឬពន្យារសុពលភាព ឬធ្វើអសុពលកម្មទិដ្ឋាការទាំងនោះ។

## មាត្រា១២
## មុខងារសារការីកម្ម និងនីត្យានុកូលកម្ម

១-មន្ត្រីកុងស៊ុលត្រូវបានផ្តល់សិទ្ធិដើម្បី ៖

ក-រៀបចំឯកសារឱ្យជនបរទេស សម្រាប់ប្រើប្រាស់ក្នុងរដ្ឋដាក់កុងស៊ុល ដោយមានការស្នើសុំពីបុគ្គលនោះ។

ខ-រៀបចំឯកសារឱ្យពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល សម្រាប់ប្រើប្រាស់ក្រៅប្រទេស ដោយមានការស្នើសុំពីពលរដ្ឋនោះ។

គ-បកប្រែឯកសារទៅជាភាសាផ្លូវការរបស់រដ្ឋដាក់កុងស៊ុល ឬរដ្ឋម្ចាស់ផ្ទះ ហើយបញ្ជាក់ថា ការបកប្រែនោះអនុលោមទៅតាមច្បាប់ដើម។

ឃ-បំពេញមុខងារសារការីផ្សេងទៀត ដែលរដ្ឋដាក់កុងស៊ុលប្រគល់ឱ្យ និង ដែលពុំមានការជំទាស់ពីរដ្ឋម្ចាស់ផ្ទះ។

ង-នីត្យានុកូលកម្មហត្ថលេខា និងត្រាលើឯកសារដែលចេញដោយអាជ្ញាធរ ពាក់ព័ន្ធ នៃរដ្ឋដាក់កុងស៊ុល ឬរដ្ឋម្ចាស់ផ្ទះ។

២-ពេលឯកសារទាំងនោះប្រើប្រាស់ក្នុងរដ្ឋម្ចាស់ផ្ទះ ឯកសារដែលបានតាក់តែង បញ្ជាក់ ឬនីត្យានុកូលកម្ម ដោយមន្ត្រីកុងស៊ុល ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ត្រូវមានសុពលភាព និងអានុភាពដូចគ្នានឹងឯកសារដែលបានតាក់តែង បញ្ជាក់ ឬ នីត្យានុកូលកម្មដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ។

៣-មន្ត្រីកុងស៊ុលត្រូវរក្សាទុកជាបណ្តោះអាសន្ននូវលិខិតបញ្ជាក់ និងឯកសាររបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ប្រសិនបើ វាមិនផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ។

## មាត្រា១៣
## ការជូនដំណឹងពីការឃុំខ្លួន ការចាប់ខ្លួន និងការសួរសុខទុក្ខ

១-ប្រសិនបើ ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលត្រូវបានឃុំខ្លួន ចាប់ខ្លួន ឬដកហូតសិទ្ធិសេរីភាព តាមមធ្យោបាយផ្សេងណាមួយ ក្នុងមណ្ឌលកុងស៊ុល ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះត្រូវជូនដំណឹង អំពីបញ្ហានេះទៅប៉ុស្តិ៍កុងស៊ុល ឱ្យបានឆាប់បំផុត ដែលអាចធ្វើទៅបាន។

២-មន្ត្រីកុងស៊ុលមានសិទ្ធិសួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលកំពុងជាប់ឃុំខ្លួន ចាប់ខ្លួន ឬដកហូតសិទ្ធិសេរីភាព តាមមធ្យោបាយណាមួយ និងចាត់ចែងជួយផ្នែកច្បាប់ឱ្យដល់ពួកគេ។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះត្រូវចាត់ចែងរៀបចំចំពោះការសួរសុខទុក្ខនេះ ឱ្យបានឆាប់បំផុត ដែលអាចធ្វើទៅបាន។

៣-មន្ត្រីកុងស៊ុលមានសិទ្ធិសួរសុខទុក្ខពលរដ្ឋ នៃរដ្ឋដាក់កុងស៊ុល ដែលកំពុងជាប់ទោស។

៤-អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនព័ត៌មានដល់ពលរដ្ឋខាងលើ អំពីបទប្បញ្ញត្តិនៃកថាខណ្ឌ ១ ២ និង ៣ នៃមាត្រានេះ។

៥-ក្នុងករណីមានការជំនុំជម្រះក្តី ឬមាននីតិវិធីផ្សេងទៀត ទៅលើពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល នៅក្នុងរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនដំណឹងទៅមន្ត្រីកុងស៊ុលនៃរដ្ឋដាក់កុងស៊ុល តាមសំណើរបស់បុគ្គលនោះ អំពីការចោទប្រកាន់ទៅលើជននោះ ព្រមទាំងពេលវេលា កាលបរិច្ឆេទ និងទីកន្លែងជំនុំជម្រះក្តី ឬនីតិវិធីផ្សេងទៀត។ មន្ត្រីកុងស៊ុលមានសិទ្ធិចូលរួមស្តាប់ការជំនុំជម្រះក្តី ឬនីតិវិធីផ្សេងទៀតទៅលើជននោះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ។

៦-មន្ត្រីកុងស៊ុលត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់រដ្ឋម្ចាស់ផ្ទះ ក្នុងការបំពេញមុខងារ ដូចមានចែងក្នុងមាត្រានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការគោរពច្បាប់ និងបទប្បញ្ញត្តិទាំងនោះមិនត្រូវដាក់កំហិតដល់ការអនុវត្តសិទ្ធិ ដូចមានចែងក្នុងមាត្រានេះ។

## មាត្រា១៤
## អាណាព្យាបាលភាព និងអាណាព្យាបាលភាព

១-អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនដំណឹងទៅប៉ុស្តិ៍កុងស៊ុល អំពីអាណាព្យាបាល ឬអាណត្តិគាហកសម្រាប់ពលរដ្ឋ រួមទាំងអនីតិជននៃរដ្ឋដាក់កុងស៊ុល ក្នុងមណ្ឌលកុងស៊ុល ដែលពុំមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើក្នុងនាមខ្លួន។

២-មន្ត្រីកុងស៊ុលត្រូវការពារ ក្នុងកម្រិតមួយដែលច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះអនុញ្ញាតឱ្យ នូវសិទ្ធិ និងផលប្រយោជន៍ពលរដ្ឋ រួមទាំងអនីតិជននៃរដ្ឋដាក់កុងស៊ុល ដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើក្នុងនាមខ្លួន ហើយប្រសិនបើចាំបាច់ ផ្តល់អនុសាសន៍ ឬចាត់តាំងអាណាព្យាបាល ឬអាណត្តិគាហកឱ្យបុគ្គលពាក់ព័ន្ធនោះ ព្រមទាំងត្រួតពិនិត្យសកម្មភាពទាក់ទងនឹងអាណាព្យាបាលភាព ឬអាណត្តិគាហកភាព។

## មាត្រា១៥
## ការទំនាក់ទំនងដល់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល

១-មន្ត្រីកុងស៊ុលត្រូវបានផ្តល់សិទ្ធិដើម្បី ៖

ក-ជួបប្រាស្រ័យទាក់ទងនឹងពលរដ្ឋ នៃរដ្ឋដាក់កុងស៊ុលក្នុងមណ្ឌលកុងស៊ុល ហើយរដ្ឋម្ចាស់ផ្ទះមិនត្រូវរឹតត្បិតដល់ការប្រាស្រ័យទាក់ទង រវាងពលរដ្ឋ

នៃរដ្ឋដាក់កុងស៊ុល និងប៉ុស្តិ៍កុងស៊ុល និងមិនអាចរឹតត្បិតដល់ការចូលទៅកាន់ប៉ុស្តិ៍កុងស៊ុលបានទេ។

ខ-ស្វែងយល់ពីលក្ខខណ្ឌជីវិត និងការបំពេញការងាររបស់ពលរដ្ឋ នៃរដ្ឋដាក់កុងស៊ុលនៅក្នុងរដ្ឋម្ចាស់ផ្ទះ ព្រមទាំងផ្តល់ការឧបត្ថម្ភចាំបាច់ដល់ពួកគេ។

គ-ស្នើសុំឱ្យអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ស្វែងរកទីកន្លែងស្នាក់នៅរបស់ពលរដ្ឋ នៃរដ្ឋដាក់កុងស៊ុល ហើយរដ្ឋម្ចាស់ផ្ទះត្រូវធ្វើឱ្យអស់លទ្ធភាពដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធ។

ឃ-ទទួល និងថែរក្សាទុកជាបណ្តោះអាសន្ននូវលុយកាក់ និងវត្ថុមានតម្លៃរបស់ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់រដ្ឋម្ចាស់ផ្ទះ។

២-ក្នុងករណីដែលពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលមិននៅទីកន្លែង ឬក៏មានហេតុផលណាមួយផ្សេងទៀត មិនអាចការពារសិទ្ធិ និងផលប្រយោជន៍ តាមកាលកំណត់ មន្ត្រីកុងស៊ុលអាចធ្វើជាអ្នកតំណាងឱ្យជននោះនៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀតនៃរដ្ឋម្ចាស់ផ្ទះ ឬរៀបចំឱ្យមានអ្នកតំណាងស្របច្បាប់ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់រដ្ឋម្ចាស់ផ្ទះ រហូតដល់ជននោះចាត់តាំងអ្នកតំណាងផ្ទាល់ខ្លួន ឬអាចបន្តដំណើរការការពារសិទ្ធិ និងផលប្រយោជន៍ផ្ទាល់ខ្លួនបាន។

## មាត្រា១៦
## ការជូនដំណឹងពីមរណភាព

ពេលទទួលដំណឹងមរណភាពរបស់ពលរដ្ឋ នៃរដ្ឋដាក់កុងស៊ុលក្នុងរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនព័ត៌មានទៅប៉ុស្តិ៍កុងស៊ុលឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅពេលមានសំណើរបស់ប៉ុស្តិ៍កុងស៊ុល ត្រូវផ្តល់លិខិតបញ្ជាក់មរណភាព ឬឯកសារចម្លងផ្សេងទៀត ដែលបញ្ជាក់ពីមរណភាព។

## មាត្រា១៧
## មុខងារទាក់ទងនឹងមរតក

១-ប្រសិនបើ ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលទទួលមរណភាព បានបន្សល់ទុកទ្រព្យនៅក្នុងរដ្ឋម្ចាស់ផ្ទះ ហើយគ្មានទាយាទ ឬអ្នកអនុវត្តមរតកសាសន៍នៅក្នុងរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះត្រូវជូនដំណឹងទៅប៉ុស្តិ៍កុងស៊ុលឱ្យបានឆាប់បំផុត។

២-មន្ត្រីកុងស៊ុល ត្រូវមានវត្តមាននៅពេលទ្រព្យដែលមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ កំពុងចុះបញ្ជីសារពើភណ្ឌ និងមានបោះត្រាសម្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ។

៣-ប្រសិនបើ ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុលជាទាយាទ ឬអច្ច័យលាភី មានសិទ្ធិស្នង និងទទួលមរតក ឬអំណោយរបស់អ្នកស្លាប់ ដែលមានសញ្ជាតិផ្សេងនៅក្នុងរដ្ឋម្ចាស់ផ្ទះ ហើយប្រសិនបើ បុគ្គលនោះមិននៅក្នុងដែនដីរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះត្រូវជូនព័ត៌មានទៅប៉ុស្តិ៍កុងស៊ុលអំពីការស្នងមរតក ឬទទួលអំណោយនេះ។

៤-ករណីដែលពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល អះអាងថាមានសិទ្ធិស្នង ឬទទួលមរតកនៅក្នុងរដ្ឋម្ចាស់ផ្ទះ ប៉ុន្តែជននោះ ឬអ្នកតំណាងជននោះ មិនអាចមានវត្តមាននៅក្នុងនីតិវិធីស្នងមរតក មន្ត្រីកុងស៊ុល ឬអនុកុងស៊ុលរបស់ខ្លួន អាចធ្វើជាតំណាងឱ្យជននោះនៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះផ្សេងទៀត។

៥-មន្ត្រីកុងស៊ុល ក្នុងនាមពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលមិនមែនជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ មានសិទ្ធិទទួលមរតក ឬអំណោយនៅក្នុងរដ្ឋម្ចាស់ផ្ទះ ដើម្បីផ្ទេរទៅឱ្យជននោះ។

៦-ប្រសិនបើ ពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ដែលមិនមែនជាអ្នករស់នៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ ទទួលមរណភាពក្នុងអំលុងពេលស្នាក់នៅបណ្តោះអាសន្ន ឬពេលឆ្លងកាត់រដ្ឋម្ចាស់ផ្ទះ ហើយប្រសិនបើ គ្មានសាច់ញាតិ ឬអ្នកតំណាង មន្ត្រីកុងស៊ុលមានសិទ្ធិថែរក្សាទុកភ្លាមៗជាបណ្តោះអាសន្ន នូវរាល់ឯកសារនានា ប្រាក់កាស និងទ្រព្យសម្បត្តិ ដែលនៅជាប់ខ្លួនរបស់អ្នកស្លាប់នោះ ដើម្បីផ្ទេរទៅឱ្យទាយាទ អ្នកអនុវត្តមរតកសាសន៍ ឬបុគ្គលផ្សេងទៀត ដែលមានការអនុញ្ញាតឱ្យទទួលទ្រព្យទាំងនោះ។

៧-មន្ត្រីកុងស៊ុលត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនានារបស់រដ្ឋម្ចាស់ផ្ទះ ក្នុងការបំពេញមុខងាររបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌ ៤ កថាខណ្ឌ ៥ និងកថាខណ្ឌ ៦ នៃមាត្រានេះ។

## មាត្រា១៨
## កិច្ចឧបត្ថម្ភដល់នាវា នាវិកបតី និងក្រុមនាវិកនៃរដ្ឋដាក់កុងស៊ុល

១-មន្ត្រីកុងស៊ុលមានសិទ្ធិផ្តល់កិច្ចឧបត្ថម្ភ ដល់នាវានៃរដ្ឋដាក់កុងស៊ុល ដែលស្ថិតនៅក្នុងដែនទឹកផ្ទៃក្នុងនៃរដ្ឋម្ចាស់ផ្ទះ និងដល់នាវិកបតី និងសមាជិកក្រុមនាវិក ព្រមទាំងមានសិទ្ធិ ៖

ក-ឡើងលើនាវា ពេលចតនៅមាត់ច្រាំង សាកសួរនាវិកបតី និងសមាជិកណាម្នាក់នៃក្រុមនាវិក ព្រមទាំងទទួលរបាយការណ៍ទាក់ទងនឹងនាវា ទំនិញលើនាវា និងការធ្វើដំណើរ។

ខ-ស៊ើបសួរឧប្បត្តិហេតុណាមួយ ដែលបានកើតមានឡើងក្នុងអំលុងពេលនៃការធ្វើដំណើរ លុះត្រាតែ ការស៊ើបសួរនេះមិនប៉ះពាល់ដល់អំណាច នៃអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ។

គ-ដោះស្រាយវិវាទរវាងនាវិកបតី និងក្រុមនាវិក រួមទាំងវិវាទទាក់ទងនឹងប្រាក់បៀវត្ស និងកិច្ចសន្យាការងារផងដែរ។

ឃ-ទទួលជួបនឹងនាវិកបតី ឬសមាជិកណាម្នាក់នៃក្រុមនាវិក ហើយប្រសិនបើចាំបាច់ សម្រួលការព្យាបាលជំងឺ និងសម្រួលការធ្វើមាតុភូមិនិវត្តន៍ទៅកាន់រដ្ឋដាក់កុងស៊ុលវិញ។

ង-ទទួលពិនិត្យ តាក់តែង ចុះហត្ថលេខា បញ្ជាក់ ឬធ្វើនីត្យានុកូលកម្មឯកសារទាក់ទងនឹងនាវា។

ច-ដោះស្រាយបញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងនាវា ដែលអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដាក់កុងស៊ុលប្រគល់ជូន។

២-នាវិកបតី និងសមាជិកណាម្នាក់នៃក្រុមនាវិកអាចទាក់ទងនឹងមន្ត្រីកុងស៊ុលបាន។ ពួកគេអាចទៅប៉ុស្តិ៍កុងស៊ុល ដោយផ្អែកលើមូលដ្ឋានថា មិនរំលោភលើច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះទាក់ទងនឹងការគ្រប់គ្រងកំពង់ផែ និងជនបរទេស។

៣-មន្ត្រីកុងស៊ុលអាចទាក់ទងនឹងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ និងស្នើសុំការគាំទ្រក្នុងការបំពេញមុខងាររបស់ខ្លួន លើរាល់បញ្ហាទាំងឡាយពាក់ព័ន្ធនឹងនាវានៃរដ្ឋដាក់កុងស៊ុល នាវិកបតី សមាជិកក្រុមនាវិក និងទំនិញ។

៤-ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលមានសិទ្ធិបង្ហាញខ្លួនជាមួយនាវិកបតី ឬសមាជិកក្រុមនាវិកនៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីជួយដល់ពួកគេ។

## មាត្រា១៩
## កិច្ចការពារក្នុងករណីមានវិធានការចាំបាច់នានាលើនាវានៃរដ្ឋដាក់កុងស៊ុល

១-ប្រសិនបើ តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៃរដ្ឋម្ចាស់ផ្ទះ មានបំណងចាត់វិធានការចាំបាច់នានា ឬចាប់ផ្តើមធ្វើការស៊ើបសួរជាផ្លូវការ លើនាវារបស់រដ្ឋដាក់កុងស៊ុល អាជ្ញាធរទាំងនោះត្រូវជូនដំណឹងជាមុនទៅប៉ុស្តិ៍កុងស៊ុល ដើម្បីឱ្យមន្ត្រីកុងស៊ុល ឬតំណាងរបស់ខ្លួនមានវត្តមាន នៅពេលគេចាត់វិធានការនោះ។ ប្រសិនបើ មានភាពបន្ទាន់រារាំងមិនឱ្យជូនដំណឹងជាមុន អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនដំណឹងទៅប៉ុស្តិ៍កុងស៊ុលជាបន្ទាន់ ក្រោយពីចាត់វិធានការ ហើយផ្តល់សេចក្តីលំអិតនៃវិធានការដែលបានចាត់ឡើងនោះ តាមសំណើរបស់មន្ត្រីកុងស៊ុល។

២-បទប្បញ្ញត្តិទាំងឡាយក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ត្រូវអនុវត្តចំពោះវិធានការស្រដៀងគ្នា ដែលត្រូវបានចាត់ឱ្យនាវិកបតី ឬសមាជិកណាម្នាក់នៃក្រុមនាវិកឡើងលើគោក ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ។

៣-បទប្បញ្ញត្តិទាំងឡាយក្នុងកថាខណ្ឌ ១ និង ២ នៃមាត្រានេះ មិនត្រូវបានអនុវត្តទេចំពោះការត្រួតពិនិត្យជាធម្មតានៃផ្នែកគយ រដ្ឋបាលកំពង់ផែ ចត្តាឡីស័ក ឬការត្រួតពិនិត្យឆ្លងដែន ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ព្រមទាំងវិធានការដទៃទៀតដែលត្រូវបានចាត់ដោយអាជ្ញាធរនោះ ដើម្បីធានាសុវត្ថិភាពនាវាចរផ្លូវសមុទ្រ ឬការទប់ស្កាត់ការបំពុលទឹក។

៤-លើកលែងតែមានសំណូមពរ ឬមានការអនុញ្ញាតពីនាវិកបតីនៃរដ្ឋដាក់កុងស៊ុល ឬមន្ត្រីកុងស៊ុល អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ មិនមានសិទ្ធិជ្រៀតជ្រែកកិច្ចការផ្ទៃ

ក្នុងនៃនាវាឡើយ នៅពេលដែលសន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈរបស់រដ្ឋម្ចាស់ផ្ទះមិនត្រូវបានរំលោភទេ។

## មាត្រា២០
## កិច្ចឧបត្ថម្ភដល់នាវានៃរដ្ឋដាក់កុងស៊ុលដែលរងមហន្តរាយ

១-ប្រសិនបើ នាវានៃរដ្ឋដាក់កុងស៊ុលទទួលរងឧប្បត្តិហេតុក្នុងដែនសមុទ្រ ឬដែនទឹកផ្ទៃក្នុងនៃរដ្ឋម្ចាស់ផ្ទះ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនដំណឹងទៅប៉ុស្តិ៍កុងស៊ុល ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ព្រមទាំងជម្រាបពីវិធានការដែលត្រូវបានចាត់ ដើម្បីសង្គ្រោះអ្នកដំណើរ នាវា ទំនិញ និងទ្រព្យសម្បត្តិដទៃទៀត។

២-មន្ត្រីកុងស៊ុលមានសិទ្ធិចាត់វិធានការនានា ដើម្បីផ្តល់កិច្ចឧបត្ថម្ភដល់នាវារងមហន្តរាយ ព្រមទាំងក្រុមនាវិក និងអ្នកធ្វើដំណើរ ហើយស្នើសុំកិច្ចឧបត្ថម្ភដូចគ្នានេះ ពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ។

៣-ប្រសិនបើនាវារងមហន្តរាយនៃរដ្ឋដាក់កុងស៊ុល ឬសម្ភារៈ ឬទំនិញ ត្រូវបានរកឃើញនៅជិតឆ្នេរ ឬនាំមកទុកឯកំពង់ផែនៃរដ្ឋម្ចាស់ផ្ទះ ហើយគ្មាននាវិកបតី ម្ចាស់នាវាភ្នាក់ងារក្រុមហ៊ុននាវា ឬក្រុមហ៊ុនធានារ៉ាប់រងនាវាមានវត្តមាន ឬមានលទ្ធភាពចាត់វិធានការសង្គ្រោះ ឬចាត់ចែងទំនិញលើនាវា អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះត្រូវជូនដំណឹងទៅប៉ុស្តិ៍កុងស៊ុល ឱ្យបានឆាប់បំផុតតាម ដែលអាចធ្វើទៅបាន។ មន្ត្រីកុងស៊ុលអាចចាត់វិធានការសមស្របនានា ក្នុងនាមម្ចាស់នាវា។

៤-នាវារងមហន្តរាយនៃរដ្ឋដាក់កុងស៊ុល ទំនិញ និងសម្ភារៈ មិនត្រូវស្ថិតនៅក្រោមកាតព្វកិច្ចគយ ឬកម្រៃស្រដៀងគ្នាផ្សេងទៀតនៃរដ្ឋម្ចាស់ផ្ទះ ដរាបណាទំនិញទាំងនោះមិនត្រូវបានលក់ និងប្រើប្រាស់នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

## មាត្រា២១
## អាកាសយាននៃរដ្ឋដាក់កុងស៊ុល

បទប្បញ្ញត្តិនៃអនុសញ្ញានេះ ទាក់ទងនឹងនាវានៃរដ្ឋដាក់កុងស៊ុល ត្រូវអនុវត្តចំពោះអាកាសយាននៃរដ្ឋដាក់កុងស៊ុល ដរាបណាការអនុវត្តនោះមិនផ្ទុយនឹងបទប្បញ្ញត្តិនៃកិច្ច

ព្រមព្រៀងទ្វេភាគីជាធរមាន ឬពហុភាគី ដែលរដ្ឋទាំងពីរជាហត្ថលេខី ព្រមទាំងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីសេវាកម្មដឹកជញ្ជូនផ្លូវអាកាស រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសទីក្រុងហុងកុង និងម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន។

## មាត្រា២២
## ការបញ្ជូនឯកសារតតិយជន

មន្ត្រីកុងស៊ុលមានសិទ្ធិបញ្ជូនឯកសារតុលាការ និងឯកសារក្រៅប្រព័ន្ធតុលាការ ក្នុងកម្រិតមួយដែលច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះអនុញ្ញាតឱ្យ ហើយដែលស្ថិតនៅក្រោមប្រតិបត្តិការនៃកិច្ចព្រមព្រៀង ដែលមានស្រាប់ រវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ។

## មាត្រា២៣
## មណ្ឌលដែលអនុវត្តនូវមុខងារកុងស៊ុល

មន្ត្រីកុងស៊ុលត្រូវបំពេញមុខងារកុងស៊ុលតែក្នុងមណ្ឌលរបស់ខ្លួន។ ប្រសិនបើ មានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ មន្ត្រីកុងស៊ុលក៏អាចបំពេញមុខងាររបស់ខ្លួន នៅក្រៅមណ្ឌលរបស់ខ្លួនបានដែរ។

## មាត្រា២៤
## ការប្រាស្រ័យទាក់ទងនឹងអាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះ

ក្នុងការបំពេញមុខងាររបស់ខ្លួន មន្ត្រីកុងស៊ុលអាចធ្វើការប្រាស្រ័យទាក់ទងនឹងអាជ្ញាធរមានសមត្ថកិច្ច ក្នុងមណ្ឌលកុងស៊ុលរបស់ខ្លួន ហើយប្រសិនបើចាំបាច់ ជាមួយអាជ្ញាធរកណ្តាលនៃរដ្ឋម្ចាស់ផ្ទះ ក្នុងកម្រិតមួយដែលច្បាប់ បទប្បញ្ញត្តិ និងទម្លាប់នៃការអនុវត្តរបស់រដ្ឋម្ចាស់ផ្ទះអនុញ្ញាតឱ្យ។

## ជំពូកទី៤
## ការសម្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

### មាត្រា២៥
### ការសម្រួលដល់ប៉ុស្តិ៍កុងស៊ុល

១-រដ្ឋម្ចាស់ផ្ទះត្រូវផ្តល់ការសម្រួលពេញលេញ ដល់ការបំពេញមុខងារនៃប៉ុស្តិ៍កុងស៊ុល។

២-រដ្ឋម្ចាស់ផ្ទះត្រូវប្រព្រឹត្តចំពោះសមាជិកនៃប៉ុស្តិ៍កុងស៊ុល ដោយការគោរព និងចាត់វិធានការសមស្របនានា ដើម្បីធានាដល់ការបំពេញមុខងារកុងស៊ុលដោយរលូន នូវសិទ្ធិការសម្រួលនានា បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ។

### មាត្រា២៦
### ការកាន់កាប់ទីស្ថានកុងស៊ុល និងលំនៅស្ថាន

១-រដ្ឋដាក់កុងស៊ុល និងតំណាងរបស់ខ្លួនមានសិទ្ធិ ក្នុងកម្រិតមួយដែលច្បាប់ និងបទប្បញ្ញត្តិនានានៃរដ្ឋម្ចាស់ផ្ទះអនុញ្ញាតឱ្យ ៖

ក-ទិញ ជួល ឬកាន់កាប់អគារ តាមមធ្យោបាយណាមួយ ឬផ្នែកណាមួយនៃអគារ និងផ្ទៃដីជាប់អគារនោះ សម្រាប់ប្រើជាទីស្ថានកុងស៊ុល និងលំនៅស្ថាននៃសមាជិកនៃប៉ុស្តិ៍កុងស៊ុល ដោយមិនរាប់បញ្ចូលលំនៅស្ថាននៃសមាជិកទាំងឡាយណា ដែលជាពលរដ្ឋ ឬអ្នករស់នៅអចិន្ត្រៃយ៍ នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

ខ-សាងសង់ ឬជួសជុលកែលំអអគារនៅលើដី ដែលកាន់កាប់។

២-រដ្ឋម្ចាស់ផ្ទះត្រូវជួយរដ្ឋដាក់កុងស៊ុល ក្នុងការកាន់កាប់ទីស្ថានកុងស៊ុល ហើយនៅពេលចាំបាច់ កាន់កាប់លំនៅស្ថានសមស្របសម្រាប់សមាជិកនៃប៉ុស្តិ៍កុងស៊ុល។

៣-ក្នុងការអនុវត្តសិទ្ធិ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ រដ្ឋដាក់កុងស៊ុល ឬតំណាងរបស់ខ្លួន ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនានានៃរដ្ឋម្ចាស់ផ្ទះ ស្តីពីដីធ្លី សំណង់ និងនគរូបនីយកម្ម។

## មាត្រា២៧
## ការប្រើទង់ជាតិ និងសញ្ញាជាតិ

១-រដ្ឋដាក់កុងស៊ុលមានសិទ្ធិប្រើប្រាស់ទង់ជាតិ សញ្ញាជាតិខ្លួននៅលើទីស្ថានកុងស៊ុល និងសញ្ញាសម្គាល់នៃប៉ុស្តិ៍កុងស៊ុលជាភាសានៃរដ្ឋដាក់កុងស៊ុល និងនៃរដ្ឋម្ចាស់ផ្ទះ។

២-រដ្ឋដាក់កុងស៊ុលមានសិទ្ធិបង្ហូតទង់ជាតិខ្លួន នៅលើទីស្ថានកុងស៊ុល លំនៅស្ថានរបស់ប្រធានប៉ុស្តិ៍កុងស៊ុល និងរថយន្តរបស់ខ្លួន ដែលប្រើប្រាស់ក្នុងពេលបំពេញមុខងារជាផ្លូវការ។

## មាត្រា២៨
## ភាពមិនអាចរំលោភបំពានបាននៃទីស្ថានកុងស៊ុល និងលំនៅស្ថានមន្ត្រីកុងស៊ុល

១-ទីស្ថានកុងស៊ុល និងលំនៅស្ថានមន្ត្រីកុងស៊ុល មិនអាចត្រូវបានរំលោភបំពានបានឡើយ។ អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះមិនអាចចូលទៅក្នុងទីស្ថានកុងស៊ុល និងលំនៅស្ថានមន្ត្រីកុងស៊ុលបានឡើយ ប្រសិនបើ គ្មានការយល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុល ឬប្រធានបេសកកម្មការទូតនៃរដ្ឋដាក់កុងស៊ុល ក្នុងរដ្ឋម្ចាស់ផ្ទះ ឬមន្ត្រី ដែលចាត់តាំងដោយប្រធានប៉ុស្តិ៍កុងស៊ុល ឬប្រធានបេសកកម្មការទូត។

២-រដ្ឋម្ចាស់ផ្ទះត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីការពារទីស្ថានកុងស៊ុល និងលំនៅស្ថានមន្ត្រីកុងស៊ុល ចំពោះការជ្រៀតចូល ឬការខូចខាត និងទប់ស្កាត់ការរំខានដល់សេចក្តីសុខសាន្តរបស់ប៉ុស្តិ៍កុងស៊ុល ឬប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់ប៉ុស្តិ៍កុងស៊ុល។

## មាត្រា២៩
## ការរួចផុតពីកំណែនទីស្ថានកុងស៊ុល

ទីស្ថានកុងស៊ុល គ្រឿងសង្ហារិម ទ្រព្យសម្បត្តិ និងមធ្យោបាយដឹកជញ្ជូនរបស់ប៉ុស្តិ៍កុងស៊ុល ត្រូវរួចផុតពីទម្រង់នៃកំណែនណាមួយ។

## មាត្រា៣០
## ភាពមិនអាចរំលោភបំពានបាននៃបណ្ណសារ និងឯកសារកុងស៊ុល

បណ្ណសារ និងឯកសារកុងស៊ុល មិនអាចត្រូវបានរំលោភបានឡើយ ទោះបីនៅពេលណា ឬកន្លែងណាក៏ដោយ។

## មាត្រា៣១
## សេរីភាពនៃការប្រាស្រ័យទាក់ទង

១-ក្នុងគោលបំណងជាផ្លូវការ រដ្ឋម្ចាស់ផ្ទះត្រូវអនុញ្ញាត និងការពារសេរីភាពក្នុងការប្រាស្រ័យទាក់ទងរបស់ប៉ុស្តិ៍កុងស៊ុល។ ក្នុងការប្រាស្រ័យទាក់ទងនឹងរដ្ឋាភិបាល បណ្ដាស្ថានបេសកកម្មការទូត និងប៉ុស្តិ៍កុងស៊ុលដទៃទៀតនៃរដ្ឋដាក់កុងស៊ុល ប៉ុស្តិ៍កុងស៊ុលអាចប្រើគ្រប់មធ្យោបាយធ្វើទំនាក់ទំនងសមស្របទាំងអស់ រួមមានសារ លិខិតជាអក្សរសម្ងាត់ ឬជាលេខសម្ងាត់ ហាវីការទូត ឬកុងស៊ុល និងហិបការទូត ឬកុងស៊ុល ក៏ប៉ុន្តែប៉ុស្តិ៍កុងស៊ុលអាចដំឡើង និងប្រើប្រាស់វិទ្យុទាក់ទងបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ។

២-លិខិតឆ្លើយឆ្លងផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុល មិនអាចត្រូវបានរំលោភបំពានបានឡើយ។ ហិបកុងស៊ុលមិនត្រូវបានបើក ឬឃាត់ទុកឡើយ។ ហិបកុងស៊ុលត្រូវមានសញ្ញាសម្គាល់ខាងក្រៅច្បាស់លាស់ និងផ្ទុកតែសារឆ្លើយឆ្លង ឯកសារផ្លូវការ និងសម្ភារៈសម្រាប់ប្រើប្រាស់ជាផ្លូវការតែប៉ុណ្ណោះ ក៏ប៉ុន្តែ ប្រសិនបើ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះមានមូលហេតុច្បាស់លាស់គួរឱ្យជឿជាក់ថា ហិបកុងស៊ុលមានផ្ទុកវត្ថុផ្សេងទៀតក្រៅពីវត្ថុដែលបានរៀបរាប់ខាងលើ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ អាចស្នើសុំបើកហិបកុងស៊ុលនោះនៅចំពោះមុខតំណាងពេញសិទ្ធិរបស់រដ្ឋដាក់កុងស៊ុល។ ប្រសិនបើ តំណាងពេញសិទ្ធិរបស់រដ្ឋដាក់កុងស៊ុលបដិសេធចំពោះសំណើនេះ ហិបកុងស៊ុលត្រូវបានបញ្ជូនទៅកាន់កន្លែងដើមវិញ។

៣-ហាវីកុងស៊ុលត្រូវតែជាពលរដ្ឋនៃរដ្ឋដាក់កុងស៊ុល ហើយមិនមែនជាអ្នករស់នៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋម្ចាស់ផ្ទះ។ ហាវីកុងស៊ុលត្រូវមានឯកសារផ្លូវការបញ្ជាក់ពីឋានៈរបស់ខ្លួន។ ហាវីកុងស៊ុលត្រូវទទួលបានសិទ្ធិ ការសម្រួលនានា បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៅក្នុងរដ្ឋម្ចាស់ផ្ទះដូចហាវីការទូតដែរ។

៤-ហិបកុងស៊ុលអាចត្រូវបានប្រគល់ឱ្យមេបញ្ជាការនាវា ឬអាកាសយាននៃរដ្ឋដាក់កុងស៊ុល។ មេបញ្ជាការ ត្រូវមានឯកសារផ្លូវការបញ្ជាក់ពីចំនួនកញ្ចប់ ដែលមាននៅក្នុងហិប។ ទោះបីជាយ៉ាងណាក៏ដោយ មេបញ្ជាការនោះមិនត្រូវបានចាត់ទុកជាហារីកុងស៊ុលទេ។ ដោយមានការសម្រួលពីអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋម្ចាស់ផ្ទះ សមាជិកនៃប៉ុស្តិ៍កុងស៊ុលអាចទៅទទួល ឬប្រគល់ដោយផ្ទាល់ និងដោយសេរី នូវហិបកុងស៊ុលពិ ឬជូនមេបញ្ជាការ។

## មាត្រា៣២
## កម្រៃ និងបន្ទុកកុងស៊ុល

១-ប៉ុស្តិ៍កុងស៊ុលអាចយកកម្រៃ និងបន្ទុកលើលិខិតស្នាមកុងស៊ុលនៅក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះ ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់រដ្ឋដាក់កុងស៊ុល។

២-ការយកកម្រៃ និងបន្ទុក ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ព្រមទាំងបង្កាន់ដៃ ត្រូវរួចផុតពីពន្ធ និងអាករនៅក្នុងរដ្ឋម្ចាស់ផ្ទះ។

៣-រដ្ឋម្ចាស់ផ្ទះត្រូវអនុញ្ញាតឱ្យប៉ុស្តិ៍កុងស៊ុល បញ្ជូនប្រាក់ចំណូល ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ទៅរដ្ឋដាក់កុងស៊ុល។

## មាត្រា៣៣
## សេរីភាពនៃការធ្វើដំណើរ

វៀរលែងតែមានច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះហាមប្រាម ឬរឹតត្បិតការចេញចូល ក្នុងតំបន់ហាមឃាត់ រដ្ឋម្ចាស់ផ្ទះត្រូវធានាដល់សមាជិកនៃប៉ុស្តិ៍កុងស៊ុល នូវសេរីភាពក្នុងការធ្វើដំណើរក្នុងដែនដីរបស់ខ្លួន។

## មាត្រា៣៤
## ភាពមិនអាចរំលោភបំពានលើរូបរាងកាយមន្ត្រីកុងស៊ុល

រូបរាងកាយមន្ត្រីកុងស៊ុលមិនត្រូវបានរំលោភបំពានឡើយ ហើយពួកគេមិនអាចត្រូវបានឃុំខ្លួន ឬចាប់ខ្លួន។ រដ្ឋម្ចាស់ផ្ទះត្រូវចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់ការរំលោភបំពាននូវសេរីភាព និងសេចក្តីថ្លៃថ្នូររបស់គេ។

## មាត្រា៣៥
## អភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការ

១-មន្ត្រីកុងស៊ុលត្រូវរួចផុតពីយុត្តាធិការតុលាការ ឬរដ្ឋបាល នៃរដ្ឋម្ចាស់ផ្ទះ លើកលែងតែក្នុងនីតិវិធីរដ្ឋប្បវេណី ៖

ក-ដែលកើតឡើងពីកិច្ចសន្យា ដែលធ្វើឡើងដោយមន្ត្រីកុងស៊ុល ក្នុងនោះមន្ត្រីនេះពុំបានបញ្ជាក់ច្បាស់លាស់ថា ខ្លួនជាភ្នាក់ងារនៃរដ្ឋដាក់កុងស៊ុល។

ខ-ដោយភាគីទីបីប្តឹងទាមទារសំណងខូចខាត បណ្តាលមកពីគ្រោះថ្នាក់ ដែលបង្កឡើងដោយយានជំនិះ នាវា ឬយន្តហោះនៅក្នុងរដ្ឋម្ចាស់ផ្ទះ។

គ-ដែលទាក់ទងនឹងអចលនទ្រព្យឯកជន នៅក្នុងរដ្ឋម្ចាស់ផ្ទះ ប្រសិនបើ មន្ត្រីកុងស៊ុលមិនកាន់កាប់តំណាងឱ្យរដ្ឋដាក់កុងស៊ុល និងដើម្បីគោលបំណងនៃប៉ុស្តិ៍កុងស៊ុល។

ឃ-ដែលទាក់ទងនឹងសន្តតិកម្មឯកជន។

ង-ដែលកើតឡើងពីសកម្មភាពវិជ្ជាជីវៈ ឬពាណិជ្ជកម្មដោយមន្ត្រីកុងស៊ុលនៅក្រៅពេលបំពេញមុខងារជាផ្លូវការ នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

២-រដ្ឋម្ចាស់ផ្ទះមិនត្រូវចាត់វិធានការអនុវត្ត ចំពោះមន្ត្រីកុងស៊ុលណាម្នាក់ លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។ បើមានវិធានការក្នុងករណីបែបនេះ ភាពមិនអាចរំលោភបំពានលើបុគ្គល និងលំនៅស្ថានរបស់មន្ត្រីកុងស៊ុល មិនត្រូវបានធ្វើឱ្យប៉ះពាល់ឡើយ។

៣-សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស និងសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល ត្រូវរួចផុតពីយុត្តាធិការតុលាការ ឬរដ្ឋបាល នៃរដ្ឋម្ចាស់ផ្ទះ ចំពោះអំពើ

ដែលបានបំពេញក្នុងមុខងាររបស់ខ្លួន លើកលែងតែនីតិវិធីរដ្ឋប្បវេណី ដូចមានចែងក្នុងកថាខណ្ឌរង ក និង ខ នៃកថាខណ្ឌ ១ នៃមាត្រានេះ។

## មាត្រា៣៦
## ភារកិច្ចផ្តល់សក្ខីកម្ម

១-មន្ត្រីកុងស៊ុលមិនមានកាតព្វកិច្ចផ្តល់ភស្តុតាងជាកសិណសាក្សីទេ។

២-សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស ឬសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល អាចត្រូវកោះហៅឱ្យផ្តល់ភស្តុតាង ក្នុងអំលុងពេលនៃនីតិវិធីតុលាការ ឬរដ្ឋបាលនៃរដ្ឋម្ចាស់ផ្ទះ។ មន្ត្រីនោះមិនត្រូវបដិសេធការផ្តល់ភស្តុតាង លើកលែងតែករណីដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រានេះ។

៣-សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស ឬសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល មិនមានកាតព្វកិច្ចផ្តល់ភស្តុតាង ទាក់ទងនឹងការបំពេញមុខងាររបស់ពួកគេ ឬធ្វើលិខិតឆ្លើយឆ្លងជាផ្លូវការណាមួយ ឬរៀបចំឯកសារទាក់ទងនឹងបញ្ហាទាំងនោះទេ។ មន្ត្រីនោះមានសិទ្ធិបដិសេធការផ្តល់ភស្តុតាងជាកសិណសាក្សីជំនាញពាក់ព័ន្ធនឹងច្បាប់នៃរដ្ឋដាក់កុងស៊ុល។

៤-ចំពោះការតម្រូវឱ្យមានភស្តុតាងពីសមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស ឬសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះត្រូវជៀសវាងការជ្រៀតជ្រែកចូលក្នុងការបំពេញមុខងាររបស់គេ។ ក្នុងលក្ខខណ្ឌដែលអាចធ្វើទៅបាន អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ អាចទៅយកភស្តុតាងទាំងនោះ នៅឯលំនៅស្ថានរបស់ពួកគេ ឬទីស្ថានកុងស៊ុល ឬទទួលចម្លើយសាក្សីពីពួកគេជាលាយលក្ខណ៍អក្សរ។

## មាត្រា៣៧
## ការរួចផុតពីសេវាកម្ម ការចុះបញ្ជីជនបរទេស និងការអនុញ្ញាតស្នាក់នៅ

១-សមាជិកនៃប៉ុស្តិ៍កុងស៊ុលត្រូវរួចផុតពីទម្រង់ណាមួយ នៃសេវាកម្មផ្ទាល់ខ្លួន សេវាសាធារណៈ និងកាតព្វកិច្ចយោធា នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

២-មន្ត្រីកុងស៊ុល និងសមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃប៉ុស្តិ៍កុងស៊ុល ត្រូវរួចផុតពីកាតព្វកិច្ចនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ពាក់ព័ន្ធនឹងការចុះបញ្ជីជនបរទេស និងការស្នាក់នៅរបស់ជនបរទេស។

## មាត្រា៣៨
## ការលើកលែងពន្ធលើទ្រព្យសម្បត្តិ

១-រដ្ឋម្ចាស់ផ្ទះត្រូវលើកលែងពន្ធ និងអាករគ្រប់បែបយ៉ាង ដោយឈរលើគោលការណ៍បដិការ និងក្នុងកម្រិតដែលច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនអនុញ្ញាតឱ្យ ដូចខាងក្រោម ៖

ក-ទីស្ថានកុងស៊ុល និងលំនៅស្ថានសមាជិកនៃប៉ុស្តិ៍កុងស៊ុលដែលទទួលបាន ក្នុងនាមនៃរដ្ឋដាក់កុងស៊ុល ឬតំណាងរបស់ខ្លួន ព្រមទាំងកិច្ចប្រតិបត្តិការជំនួញ ឬឧបករណ៍ផ្សេងទៀតដែលនៅទីនោះ។

ខ-ឧបករណ៍ប្រើប្រាស់ ក្នុងកិច្ចការកុងស៊ុល និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ផ្តាច់មុខ សម្រាប់កិច្ចការជាផ្លូវការ ព្រមទាំងការទទួលបានការកាន់កាប់ ឬការថែរក្សាផងដែរ។

២-បទប្បញ្ញត្តិនៃកថាខណ្ឌ ១ នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះ ៖

ក-បន្ទុកលើសេវាកម្មពិសេស។

ខ-ពន្ធ និងអាករដែលអាចប្រមូលបានពីបុគ្គល ដែលចុះកិច្ចសន្យាជាមួយរដ្ឋដាក់កុងស៊ុល ឬតំណាងរបស់ខ្លួន ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ។

## មាត្រា៣៩
## ការលើកលែងពន្ធរបស់សមាជិកនៃប៉ុស្តិ៍កុងស៊ុល

១-មន្ត្រីកុងស៊ុល និងសមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃប៉ុស្តិ៍កុងស៊ុល ត្រូវរួចផុតពី ពន្ធ និងអាករជាតិ តំបន់ ឬខេត្តក្រុងនៃរដ្ឋម្ចាស់ផ្ទះ លើបុគ្គល ឬវត្ថុ លើកលែងតែ ៖

ក-ពន្ធមិនផ្ទាល់ ដែលធម្មតាត្រូវបានបញ្ចូលនៅក្នុងតម្លៃទំនិញ ឬសេវា។

ខ-ពន្ធ និងអាករលើអចលនវត្ថុឯកជន ដែលស្ថិតក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះ ក្រៅពីបញ្ញត្តិក្នុងកថាខណ្ឌរង ក នៃកថាខណ្ឌ ១ នៃមាត្រា ៣៨ នៃអនុសញ្ញានេះ។

គ-អចលនទ្រព្យ និងបន្ទុកលើទ្រព្យសម្បត្តិមរតក និងការផ្ទេរមរតក ក្រៅពីបញ្ញត្តិនៃមាត្រា ៤៣ នៃអនុសញ្ញានេះ។

ឃ-ពន្ធ និងអាករលើប្រាក់ចំណូលឯកជន ក្រៅពីប្រាក់ចំណូលដែលទទួលបានពីមុខងារកុងស៊ុល នៅក្នុងរដ្ឋម្ចាស់ផ្ទះ។

ង-បន្ទុកលើសេវាកម្មមានកម្រៃជាក់លាក់។

ច-ពន្ធចុះបញ្ជី ពន្ធប្រាក់ប្រដាប់ក្តី ពន្ធបញ្ចាំ និងពន្ធតែមប្រ៍ ក្រៅពីបញ្ញត្តិក្នុងកថាខណ្ឌ ១ នៃមាត្រា ៣៨ នៃអនុសញ្ញានេះ។

២- សមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុលត្រូវរួចផុតពីពន្ធ និងអាករ ក្នុងរដ្ឋម្ចាស់ផ្ទះ លើប្រាក់បៀវត្សដែលពួកគេទទួលបាននៅក្នុងប៉ុស្តិ៍កុងស៊ុល។

## មាត្រា៥០
## ការលើកលែងពន្ធ និងអាករ និងការត្រួតពិនិត្យគយ

១-ស្របតាមច្បាប់ និងបទប្បញ្ញត្តិខ្លួន រដ្ឋម្ចាស់ផ្ទះត្រូវអនុញ្ញាតឱ្យនាំចេញ នាំចូល និងលើកលែងពន្ធគយទាំងអស់ និងបន្ទុកពាក់ព័ន្ធដទៃទៀត ក្រៅពីសោហ៊ុយរក្សាទុកក្នុងឃ្លាំង សោហ៊ុយដឹកជញ្ជូន និងសេវាប្រហាក់ប្រហែលដទៃទៀត លើ ៖

ក-សម្ភារៈប្រើប្រាស់ជាផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុល។

ខ-សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់មន្ត្រីកុងស៊ុល។

គ-សម្ភារៈនាំចូលសម្រាប់តាំងទីលើកដំបូង សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដោយសមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃប៉ុស្តិ៍កុងស៊ុល រួមទាំងគ្រឿងឧបភោគ និងបរិភោគ។

២-សម្ភារៈប្រើប្រាស់ ដែលមានចែងក្នុងកថាខណ្ឌរង ខ និង គ នៃកថាខណ្ឌ ១ នៃមាត្រានេះ មិនត្រូវលើសពីបរិមាណចាំបាច់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលពាក់ព័ន្ធ។

៣-ហិបអីវ៉ាន់ផ្ទាល់ខ្លួនរបស់មន្ត្រីកុងស៊ុល ត្រូវរួចផុតពីការត្រួតពិនិត្យគយ។ ហិបអីវ៉ាន់នេះអាចត្រូវពិនិត្យបានដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ លុះត្រាតែមានហេតុផលមុតមាំគួរឱ្យជឿជាក់ថា ហិបនោះមានផ្ទុកវត្ថុផ្សេងក្រៅពីវត្ថុដូចមានចែងក្នុងកថាខណ្ឌរង ខ នៃកថាខណ្ឌ ១ នៃមាត្រានេះ ឬវត្ថុនាំចេញ នាំចូល ដែលត្រូវបានហាមឃាត់ដោយច្បាប់ និងបទប្បញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ ឬក៏វត្ថុដែលស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិ

ស្តីពីចត្តាឡីស័ករបស់រដ្ឋនេះ។ ការត្រួតពិនិត្យបែបនេះ ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីកុងស៊ុលពាក់ព័ន្ធ ឬតំណាងរបស់ខ្លួន។

## មាត្រា៤១
## បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់សមាជិកគ្រួសារ

សមាជិកគ្រួសាររបស់មន្ត្រីកុងស៊ុល និងសមាជិកគ្រួសារនៃសមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស នៃប៉ុស្តិ៍កុងស៊ុលត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដាច់ដោយឡែកពីគ្នា ដូចមន្ត្រីកុងស៊ុល និងសមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស ស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។ សមាជិកក្រុមគ្រួសារនៃសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុលត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចសមាជិកនៃបុគ្គលិកបម្រើការងារ ស្របតាមកថាខណ្ឌ ១ នៃមាត្រា ៣៧ នៃអនុសញ្ញានេះ លើកលែងតែអ្នកទាំងនោះ ដែលជាពលរដ្ឋ ឬអ្នករស់នៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ ឬដែលបំពេញការងាររកកម្រៃឯកជននៅក្នុងរដ្ឋម្ចាស់ផ្ទះ។

## មាត្រា៤២
## បុគ្គលដែលមិនត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១-សមាជិកបុគ្គលិករដ្ឋបាល និងបច្ចេកទេស ឬសមាជិកនៃបុគ្គលិកបម្រើការងារនៃប៉ុស្តិ៍កុងស៊ុល ដែលជាពលរដ្ឋ ឬអ្នកដែលរស់នៅអចិន្ត្រៃយ៍ ក្នុងរដ្ឋម្ចាស់ផ្ទះ មិនត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានរៀបរាប់ក្នុងអនុសញ្ញានេះ ក្រៅពីបញ្ញត្តិក្នុងកថាខណ្ឌ ៣ នៃមាត្រា ៣៦ នៃអនុសញ្ញានេះ។

២-សមាជិកគ្រួសារនៃបុគ្គល ដែលមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ មិនត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ។

## មាត្រា៤៣
## កេរមរតករបស់សមាជិកនៃប៉ុស្តិ៍កុងស៊ុល

ក្នុងករណីដែលសមាជិកណាម្នាក់នៃប៉ុស្តិ៍កុងស៊ុល ឬសមាជិកគ្រួសាររបស់គេទទួលមរណភាព រដ្ឋម្ចាស់ផ្ទះត្រូវ ៖

ក-អនុញ្ញាតឱ្យនាំចេញនូវចលនទ្រព្យរបស់សព លើកលែងតែទ្រព្យសម្បត្តិណាដែលទទួលបានក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះ ហើយដែលការនាំចេញនូវចលនទ្រព្យនោះត្រូវហាមឃាត់ នៅពេលជននោះទទួលមរណភាព។

ខ-លើកលែងការប្រមូលពន្ធ អាករ និងបន្ទុកទាំងឡាយពាក់ព័ន្ធនឹងចលនទ្រព្យរបស់សព។

## មាត្រា៤៤
## ការផ្តើម និងការបញ្ចប់នៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១-រាល់សមាជិកនៃប៉ុស្តិ៍កុងស៊ុលត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ ចាប់ពីពេលដែលគេបានមកដល់ដែនដីនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីមកកាន់មុខតំណែងរបស់ខ្លួន ឬប្រសិនបើ គេបានមកដល់ដែនដីនោះរួចហើយ គឺចាប់ពីពេលចូលបំពេញភារកិច្ចរបស់ខ្លួនក្នុងប៉ុស្តិ៍កុងស៊ុល។

២-សមាជិកគ្រួសាររបស់សមាជិកនៃប៉ុស្តិ៍កុងស៊ុល ត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ ចាប់ពីថ្ងៃដែលសមាជិកនៃប៉ុស្តិ៍កុងស៊ុលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ។ ក្នុងករណី ពួកគេចូលក្នុងដែនដីនៃរដ្ឋម្ចាស់ផ្ទះ ឬក្លាយជាសមាជិកនៃក្រុមគ្រួសារនោះ បន្ទាប់ពីសមាជិកនៃប៉ុស្តិ៍កុងស៊ុលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ពួកគេត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ចាប់ពីថ្ងៃដែលគេបានចូល ឬក្លាយជាសមាជិកគ្រួសារនោះ។

៣-នៅពេលមុខងាររបស់សមាជិកនៃប៉ុស្តិ៍កុងស៊ុល ត្រូវបញ្ចប់ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់គេ ក៏ដូចជារបស់សមាជិកនៃក្រុមគ្រួសារគេក៏ត្រូវបញ្ចប់ នៅពេលជនទាំងនោះចាកចេញពីរដ្ឋម្ចាស់ផ្ទះ ឬពេលផុតកំណត់នៃរយៈពេលមួយសមស្របសម្រាប់ការចាកចេញដំណើរ។ ពួកគេត្រូវអស់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងនោះ នៅពេលដែលខ្លួនឈប់ជាសមាជិកក្រុមគ្រួសារនៃសមាជិកប៉ុស្តិ៍កុងស៊ុល។ ប៉ុន្តែ ប្រសិនបើបុគ្គលទាំងនោះមានបំណងចាកចេញពីរដ្ឋម្ចាស់ផ្ទះក្នុងរយៈពេលសមស្របណាមួយ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ពួកគេ ត្រូវតែនៅមានរហូតដល់ពេលចាកចេញដំណើររបស់ពួកគេ។

៤-ក្នុងករណីដែលសមាជិកនៃប៉ុស្តិ៍កុងស៊ុលទទួលមរណភាព សមាជិកគ្រួសារនៃជននោះ នៅតែទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ រហូតដល់គេចាកចេញពីដែនដីនៃ

រដ្ឋម្ចាស់ផ្ទះ ឬហួសពេលផុតកំណត់នៃរយៈពេលសមស្របណាមួយសម្រាប់ការចាកចេញដំណើរ។

## មាត្រា៤៥
## ការបដិសេធចោលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១-រដ្ឋដាក់កងស៊ីវិលអាចបដិសេធចោលផ្នែកខ្លះនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិចំពោះបុគ្គលដែលពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ៣៥ និង ៣៦ នៃអនុសញ្ញានេះ។ ការបដិសេធនេះត្រូវធ្វើដោយជាក់លាក់ នៅគ្រប់ករណីទាំងអស់ និងត្រូវជូនដំណឹងទៅរដ្ឋម្ចាស់ផ្ទះជាលាយលក្ខណ៍អក្សរ។

២-ការធ្វើបណ្តឹងអំពីបញ្ហាណាមួយដោយមន្ត្រីកងស៊ីវិល ដែលមានអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការ ស្របតាមអនុសញ្ញានេះ ត្រូវរារាំងមន្ត្រីកងស៊ីវិលនោះ មិនឱ្យលើកអះអាងថា ខ្លួនមានអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការទេ ចំពោះបណ្តឹងតបដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបណ្តឹងដើម។

៣-ការបដិសេធចោលនូវអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការ សម្រាប់គោលបំណងនៃការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងរដ្ឋបាល មិនមានន័យថា ជាការបដិសេធនូវអភ័យឯកសិទ្ធិ នៃការអនុវត្តសេចក្តីសម្រេចតុលាការឡើយ។ ក្នុងករណីអនុវត្តសេចក្តីសម្រេចតុលាការ ការបដិសេធអភ័យឯកសិទ្ធិ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដាច់ដោយឡែកជាចាំបាច់។

## ជំពូកទី៥
## បទប្បញ្ញត្តិទូទៅ

## មាត្រា៤៦
## ការគោរពច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ

១-ដោយមិនមានផលប៉ះពាល់ដល់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ពួកគេ បុគ្គលទាំងឡាយដែលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញានេះ ត្រូវមានកាតព្វកិច្ចគោរពច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ រួមទាំងច្បាប់ និងបទប្បញ្ញត្តិទាំង

ឡាយដែលគ្រប់គ្រងចរាចរណ៍។ ពួកគេក៏មានភារកិច្ចមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងនៃរដ្ឋម្ចាស់ផ្ទះ។

២-ទីស្ថានកុងស៊ុលមិនត្រូវប្រើប្រាស់ក្នុងលក្ខណៈណាមួយ ដែលផ្ទុយពីក្របខណ្ឌនៃមុខងារកុងស៊ុល។

៣-ប៉ុស្តិ៍កុងស៊ុល សមាជិកនៃប៉ុស្តិ៍កុងស៊ុល ព្រមទាំងសមាជិកក្រុមគ្រួសារពួកគេត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ទាក់ទងនឹងការធានារ៉ាប់រងយានយន្ត។

៤-សមាជិកនៃប៉ុស្តិ៍កុងស៊ុល ដែលរដ្ឋដាក់កុងស៊ុល បញ្ជូនមកប្រចាំនៅរដ្ឋម្ចាស់ផ្ទះ មិនត្រូវជាប់ពាក់ព័ន្ធក្នុងសកម្មភាពវិជ្ជាជីវៈ ឬពាណិជ្ជកម្មក្នុងរដ្ឋម្ចាស់ផ្ទះ ក្រៅពីមុខងារកុងស៊ុលរបស់ខ្លួនឡើយ។

## មាត្រា៤៧
## ការបំពេញមុខងារកុងស៊ុលដោយស្ថានបេសកកម្មការទូត

១-ស្ថានបេសកកម្មការទូតនៃរដ្ឋដាក់កុងស៊ុល ក្នុងរដ្ឋម្ចាស់ផ្ទះ អាចបំពេញមុខងារកុងស៊ុលបាន។ សិទ្ធិ និងកាតព្វកិច្ចរបស់មន្ត្រីកុងស៊ុល ដូចមានចែងក្នុងអនុសញ្ញានេះ ត្រូវអនុវត្តចំពោះបុគ្គលិកការទូតនៃរដ្ឋដាក់កុងស៊ុលដែលទទួលភារកិច្ចមុខងារកុងស៊ុល។

២-ស្ថានបេសកកម្មការទូតនៃរដ្ឋដាក់ទូត ត្រូវជូនដំណឹងទៅក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះនូវឈ្មោះ និងឋានៈនៃបុគ្គលិកការទូត ដែលទទួលភារកិច្ចមុខងារកុងស៊ុល។

៣-បុគ្គលិកការទូត ដែលទទួលភារកិច្ចមុខងារកុងស៊ុល នៅតែបន្តទទួលបានសិទ្ធិការសម្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលផ្តល់ជូន ដើម្បីជាប្រយោជន៍ដល់អ្នកការទូតស្របតាមឋានៈរបស់គេ។

## មាត្រា៤៨
## ការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត

ភាគីចុះកិច្ចសន្យា ទទួលស្គាល់ប្រការនានានៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងកុងស៊ុល ដែលបានធ្វើនៅទីក្រុងវីយែន ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៦៣ និងឯកភាពថា រាល់បញ្ហាទាំងឡាយណាដែលពុំមានចែងក្នុងអនុសញ្ញានេះ ត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងកុងស៊ុល។

### មាត្រា៤៩
### ការអនុវត្តអនុសញ្ញា

អនុសញ្ញានេះត្រូវអនុវត្ត ក្នុងពេលជំណាលគ្នា ចំពោះតំបន់រដ្ឋបាលពិសេសទីក្រុងហុងកុង និងម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន។

## ជំពូកទី៦
## អវសានបញ្ញត្តិ

### មាត្រា៥០
### ការផ្តល់សច្ចាប័ន ការចូលជាធរមាន និងការបញ្ចប់នៃអនុសញ្ញានេះ

១-អនុសញ្ញានេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ហើយត្រូវចូលជាធរមាន ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃផ្លាស់ប្តូរលិខិតុបករណ៍សច្ចាប័ន។

២-អនុសញ្ញានេះត្រូវនៅជាធរមានរយៈពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលភាគីចុះកិច្ចសន្យាណាមួយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅភាគីចុះកិច្ចសន្យាម្ខាងទៀតអំពីចេតនារបស់ខ្លួនក្នុងការបញ្ចប់អនុសញ្ញានេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០ ជាពីរច្បាប់ដើម ជាភាសាខ្មែរ ចិន និងអង់គ្លេស។ រាល់អត្ថបទទាំងអស់មានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយផ្ទុយគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកជាអត្ថបទគោល។

**តំណាងព្រះរាជាណាចក្រកម្ពុជា** **តំណាងសាធារណរដ្ឋប្រជាមានិតចិន**